ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៧ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន UNION DEVELOPMENT GROUP CO., LTD ខេត្តកោះកុង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយវិវាទ នៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Union Development Group Co., Ltd នៅខេត្តកោះកុង ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សាយ សំអាល់** | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម នាយឧត្តមសេនីយ៍ **គន់ គីម** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៣- ឯកឧត្តម **សុខ ចិន្តា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥- ឯកឧត្តម **កើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៦- ឯកឧត្តម **ប៊ុន លើត** | អភិបាលនៃគណៈអភិបាលខេត្តកោះកុង | អនុប្រធានអចិន្ត្រៃយ៍ |
| ៧- ឯកឧត្តម **គឹមរ៉េត សំរេច** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៨- ឯកឧត្តម **ប៉ុល លឹម** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩- ឯកឧត្តម **ទី សុគន្ធ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០- ឯកឧត្តម ឧត្តមសេនីយ៍ឯក **មៀច សុផាន់ណា** | អនុប្រធានក្រុមការងារថ្នាក់ជាតិ ខេត្តកោះកុង | សមាជិក |
| ១១- ឯកឧត្តម **ឈិត បូរ៉ាឌុច** | មេធាវីរាជរដ្ឋាភិបាលកម្ពុជា | សមាជិក |
| ១២- ឯកឧត្តម **សួរ ឌិចឆ័រ** | ទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **យុន ឈុនី** | អគ្គស្នងការរងនគរបាលជាតិ | សមាជិក |
| ១៤- ឧត្តមសេនីយ៍ទោ **ជា សំណាង** | នាយរងសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៥- លោក **សៅ ផល្លា** | តំណាងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១៦- ឯកឧត្តម **ចាយសាមិត្ត** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ | លេខាធិការ។ |

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីភារកិច្ច និងបេសកម្មដូចតទៅ៖

- ធ្វើការសម្របសម្រួល និងដំណោះស្រាយបញ្ហាវិវាទ នៅលើទីតាំងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Union Development Group Co., Ltd

- ចូលរួមពិភាក្សា ផ្តល់យោបល់ លើការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Union Development Group Co., Ltd
- ចូលរួមពិភាក្សា ផ្តល់យោបល់ និងដោះស្រាយលើរាល់ទម្រង់ប័ណ្ណសម្គាល់សិទ្ធិ និងលិខិតពាក់ព័ន្ធនឹងការកាន់កាប់ ប្រើប្រាស់ដីធ្លីក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុនUnion Development Group Co., Ltd
- លើកវិធានការទប់ស្កាត់ និងដោះស្រាយជាបន្ទាន់ នូវរាល់សម្មភាពអនាធិបតេយ្យ ដែលកើតមានឡើងលើទីតាំងគម្រោងវិនិយោគរបស់ក្រុមហ៊ុន Union Development Group Co., Ltd
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣.-**

បណ្តាសមាជិកគណៈកម្មការអន្តរក្រសួង ដែលតំណាងឱ្យក្រសួង ស្ថាប័ន ខេត្ត ពាក់ព័ន្ធត្រូវចូលរួមទទួលខុសត្រូវក្នុងក្របខណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានចែងក្នុងប្រការ២ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ដើម្បីបូកសរុបលទ្ធផលការងារដែលសម្រេចបានជូនរាជរដ្ឋាភិបាល។

**ប្រការ៤.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន និងមានលេខាធិការមួយ ដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន។

**ប្រការ៥.-**

សេចក្តីសម្រេច ១០៤សសរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហាវិវាទនៅក្នុងគម្រោងវិនិយោគអភិវឌ្ឍន៍ របស់ក្រុមហ៊ុន Union Development Group Co., Ltd នៅខេត្តកោះកុង និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តកោះកុង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ដូចប្រការ៦
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញដំណើរការអនុវត្តគម្រោង ហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន តភ្ជាប់ពី រាជធានីភ្នំពេញ ទៅខេត្តព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីជំរុញការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន (Expressway) តភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ ដែលស្នើវិនិយោគដោយក្រុមហ៊ុន China Road and Bridge Corporation (CRBC) ក្រោមក្របខ័ណ្ឌ សាងសង់-ធ្វើអាជីវកម្ម-ផ្ទេរ (Built-Operate-Transfer) ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ប្រធាន |
| ២- | ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | អនុប្រធាន |
| ៣- | ឯកឧត្តម **សុខ ចិន្តាសោភា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |

| | | | |
|---|---|---|---|
| ៤- | ឯកឧត្តម **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិកអចិន្ត្រៃយ៍ |
| ៥- | ឯកឧត្តម **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦- | ឯកឧត្តម **ហ៊ឹង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧- | ឯកឧត្តម **ស៊្រុន ធីរិទ្ធ** | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៨- | ឯកឧត្តម **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៩- | ឯកឧត្តម **ម៉ែន សុផល** | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១០- | ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- | ឯកឧត្តម **ផែង សុទិដ្ឋានោ** | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១២- | ឯកឧត្តម **ឆា ដុប** | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ១៣- | ឯកឧត្តម **ប៉ា សុជាតិវង្ស** | អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១៤- | ឯកឧត្តម **ផៃ ប៊ុនឈឿន** | អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | សមាជិក |
| ១៥- | ឯកឧត្តម **អ៊ូ សំអ៊ួន** | អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ | សមាជិក |
| ១៦- | ឯកឧត្តម **ខុយ ឃុនហ៊ួរ** | អភិបាលនៃគណៈអភិបាលខេត្តកំពត | សមាជិក |
| ១៧- | ឯកឧត្តម **ប៊ុន លើត** | អភិបាលនៃគណៈអភិបាលខេត្តកោះកុង | សមាជិក |
| ១៨- | ឯកឧត្តម **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក។ |

**ប្រការ២ ._**

គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- ពិនិត្យ ផ្តល់យោបល់អំពីនីតិវិធី ក្របខ័ណ្ឌគតិយុត្ត និងរូបភាពនៃការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន រាជធានីភ្នំពេញ-ខេត្តព្រះសីហនុ
- ជំរុញគម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនខាងលើ ឱ្យបានសម្រេចជាស្ថាពរ ដើម្បីរួមចំណែកពន្លឿនការអភិវឌ្ឍច្រករបៀង រាជធានីភ្នំពេញ-ខេត្តព្រះសីហនុ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៣ ._**

គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់។

**ប្រការ៤ ._**

អនុប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មការនេះ មានសិទ្ធិអញ្ជើញតំណាងពីក្រសួង-ស្ថាប័ននានា ឱ្យចូលរួមដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងករណីចាំបាច់។

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ